**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា**
**អគ្គលេខាធិការដ្ឋាន**

# បទបង្ហាញ

# ស្តីពី

# ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

**រៀបចំដោយ៖** ក្រុមការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
ប្រចាំអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.**
២០២៤

# ការប្រកាសឱ្យប្រើប្រាស់ច្បាប់






**ជំពូកទី៩**
**អវសានប្បញ្ញត្តិ**

**មាត្រា៤៦** .– ការបាត់បង់អានុភាពនៃច្បាប់ចាស់

ច្បាប់ស្ដីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ និងច្បាប់ស្ដីពីវិសោធនកម្មមាត្រា៣ មាត្រា២៩ និងមាត្រា៣០នៃច្បាប់ស្ដីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៦ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៣ ត្រូវបាត់បង់អានុភាព និងជំនួសដោយច្បាប់នេះ បន្ទាប់ពីការចូលជាធរមាន។

**មាត្រា៤៧** .– ការប្រកាសឱ្យប្រើ

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ៧កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០២០

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

២៦/២៦

ច្បាប់ស្ដីពីការប្រឆាំងការសម្អាតប្រាក់
និងហិរញ្ញប្បទានភេរវកម្ម ត្រូវបាន
ប្រកាសឱ្យប្រើប្រាស់ដោយ
ព្រះរាជក្រមលេខ
នស/រកម/០៦២០/០២១
ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០

# មាតិកា

ជំពូកទី១៖ បទប្បញ្ញត្តិទូទៅ

ជំពូកទី២៖ បុគ្គលរាយការណ៍

ជំពូកទី៣៖ វិធានការត្រូវប្រកាន់យកដោយបុគ្គលរាយការណ៍

ជំពូកទី៤៖ ស្ថាប័នប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

ជំពូកទី៥៖ បទប្បញ្ញត្តិផ្សេងៗ

ជំពូកទី៦៖ ការបង្កក ការឃាត់ទុក និងការរឹបអូស

ជំពូកទី៧៖ ទោសប្បញ្ញត្តិ និង

ជំពូកទី៨៖ អន្តរប្បញ្ញត្តិ

# ជំពូកទី១៖ បទប្បញ្ញត្តិទូទៅ

**មាត្រា១**. ច្បាប់នេះមានគោលបំណង ជានាការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដោយកំណត់អំពីវិធានការត្រួតពិនិត្យ បង្ការ ទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**មាត្រា២**. ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅក្នុងព្រះរាជាណាចក្រ-កម្ពុជា។

# ជំពូកទី១៖ បទប្បញ្ញត្តិទូទៅ (ត)

## មាត្រា៣. និយមន័យនៃពាក្យសម្អាតប្រាក់



# ជំពូកទី១៖ បទប្បញ្ញត្តិទូទៅ (ត)

## មាត្រា៣. និយមន័យ

- ហិរញ្ញប្បទានភេរវកម្ម
- ផលនៃបទល្មើស/សំអាងនៃបទល្មើស
- ទ្រព្យសម្បត្តិ
- ក្រសួង ស្ថាប័នត្រួតពិនិត្យ
- បុគ្គលពាក់ព័ន្ធនយោបាយ

- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (**ស.ហ.ក**)
- ប្រតិបត្តិការសង្ស័យ
- ប្រតិបត្តិការសាច់ប្រាក់
- ទណ្ឌកម្មហិរញ្ញវត្ថុតាមគោលដៅ
- វិធានការប្រឆាំង

# ជំពូកទី២៖ បុគ្គលរាយការណ៍

**មាត្រា៤.** **ប្រភេទបុគ្គលរាយការណ៍ចំណុះច្បាប់នេះ**

១. ធនាគារ រួមទាំងសាខាធនាគារបរទេស

២. គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ រួមមានក្រុមហ៊ុនដើងសារមូលបត្រ និងក្រុមហ៊ុនធានារ៉ាប់រង

៣. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

៤. សហករណ៍ឥណទាន

៥. ក្រុមហ៊ុនភតិសន្យា មូលនិធិសោធន និងវិនិយោគ ក្រុមហ៊ុនវិនិយោគ និងក្រុមហ៊ុនគ្រប់គ្រងមូលនិធិវិនិយោគ

៦. អាជីវកម្មប្តូរប្រាក់

៧. សេវាផ្ទេរប្រាក់

៨. បរធនបាលកិច្ច

៩. ភ្នាក់ងារ ក្រុមហ៊ុន អ្នកអភិវឌ្ឍន៍អចលនទ្រព្យ អគារ និងដីធ្លី

១០. ឈ្មួញលោហធាតុ ត្បូងថ្មមានតម្លៃ

១១. ការិយាល័យប្រៃសណីយ៍ដែលធ្វើប្រតិបត្តិការទូទាត់សងប្រាក់

១២. មេធាវី សារការី គណនេយ្យករ សវនករ ទីប្រឹក្សាវិនិយោគ និងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ

**១៣. កាស៊ីណូ និងគ្រឹះស្ថានល្បែងស៊ីសងផ្សេងៗ**

១៤. អង្គការមិនមែនរដ្ឋាភិបាល និងអង្គការមូលនិធិ

១៥. បុគ្គល ឬវិជ្ជាជីវៈផ្សេងទៀតកំណត់ដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

**មាត្រា៥.** កំណត់ពីសកម្មភាពអាជីវកម្មរបស់បុគ្គលរាយការណ៍

# ជំពូកទី៣៖ វិធានការត្រួតប្រកាន់យកដោយបុគ្គលរាយការណ៍

**មាត្រា៦. ការសម្ងាត់វិជ្ជាជីវៈ**

បុគ្គលរាយការណ៍មិនអាចយកការសម្ងាត់ធនាគារ ឬវិជ្ជាជីវៈមករារាំងការអនុវត្តច្បាប់នេះ និងប្រើជាសំអាងដើម្បីបដិសេធការផ្តល់ព័ត៌មានដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងក្រសួង ស្ថាប័នត្រួតពិនិត្យ ទោះបីសម្រាប់គោលបំណងសហប្រតិបត្តិការក្នុងប្រទេស ឬអន្តរជាតិ ឬក៏ដូចដែលបានតម្រូវក្នុងការស៊ើបអង្កេតពាក់ព័ន្ធដល់ការសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម ដែលត្រូវបានបញ្ជាដោយ ឬអនុវត្តក្រោមការត្រួតពិនិត្យរបស់តុលាការ។

**មាត្រា៧. ហាមឃាត់គណនីអនាមិក ឬផលិតផលសទិស៖** បុគ្គលរាយការណ៍មិនត្រូវ៖

១. បើក ឬរក្សាទុកគណនីអនាមិក ឬគណនីដែលមានតែលេខ ឬគណនីដែលដាក់ឈ្មោះ បតិរូបកម្ម

២. បេញផ្សាយ រក្សាទុក ឬទទួលយកផលិតផលហិរញ្ញវត្ថុផ្សេងទៀត លើកលែងតែបានអនុវត្តវិធានការយកចិត្តទុកដាក់ចំពោះអតិថិជនស្របតាមមាត្រា៨ នៃច្បាប់នេះ។

# ជំពូកទី៣៖ វិធានការត្រូវប្រកាន់យកដោយបុគ្គលរាយការណ៍ (ត)

**មាត្រា៨. វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន**

១. អនុវត្តវិធីសាស្ត្រផ្អែកលើហានិភ័យ

២. អនុវត្តតាមកម្រិតកំណត់ និងកម្រិតហានិភ័យ ស្របតាមសេចក្តីណែនាំរបស់ **ស.ហ.ក**

៣. អនុវត្តវិធានការសាមញ្ញ (ហានិភ័យទាប)

៤. កំណត់ និងផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជន

៥. ការចាត់វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន

៦. បង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដើម្បីគ្រប់គ្រង និងកាត់បន្ថយហានិភ័យ

៧. អនុវត្តវិធានការប្រឆាំងចំពោះយុត្តាធិការបរទេស ដែលមានហានិភ័យខ្ពស់ ស្របតាមការតម្រូវរបស់ក្រុមការងារហិរញ្ញវត្ថុ ឬក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក ស្តីពីការសម្អាតប្រាក់

៨. អនុវត្តវិធានការដាក់ទណ្ឌកម្មហិរញ្ញវត្ថុតាមគោលដៅ ឬវិធានការបន្ទឹង (ហានិ-ភ័យខ្ពស់)

# ជំពូកទី៣៖ វិធានការត្រូវប្រកាន់យកដោយបុគ្គលរាយការណ៍ (ត)

**មាត្រា៩**. ការសម្គាល់អត្តសញ្ញាណអតិថិជនដែលធ្វើប្រតិបត្តិការក្រោមកម្រិតកំណត់

ត្រូវអនុវត្តក្នុងករណីដែលប្រតិបត្តិការដាច់ៗពីគ្នា ត្រូវបានធ្វើឡើងច្រើនដង ដោយប្រតិបត្តិការនីមួយៗមានចំនួនទឹកប្រាក់តិចជាងចំនួនដែលបានកំណត់ដោយ **ស.ហ.ក**។

**មាត្រា១០**. ការតាមដានត្រួតពិនិត្យពិសេសទៅលើប្រតិបត្តិការមួយចំនួន

ត្រូវយកចិត្តទុកដាក់ពិសេសលើ៖

- ប្រតិបត្តិការដែលស្មុគស្មាញ មិនប្រក្រតី មានចំនួនទឹកប្រាក់ច្រើន ឬមិនបង្ហាញពីគោលបំណងសេដ្ឋកិច្ច
- អតិថិជនមិនបានជួបប្រាស្រ័យផ្ទាល់ជាមួយ
- ប្រតិបត្តិការជាមួយបុគ្គលពាក់ព័ន្ធនយោបាយ
- ធ្វើតាមរយៈធនាគារទំនាក់ទំនង

# ជំពូកទី៣៖ វិធានការត្រូវប្រកាន់យកដោយបុគ្គលរាយការណ៍ (ត)

**មាត្រា១១.** ការរក្សាទុកឯកសារកត់ត្រារបស់បុគ្គលរាយការណ៍

ត្រូវរក្សាទុកឯកសារកត់ត្រាអត្តសញ្ញាណ និងប្រតិបត្តិការរបស់អតិថិជនឱ្យបានយ៉ាងតិច ៥ ឆ្នាំ ក្រោយគណនីត្រូវបិទ ឬទំនាក់ទំនងអាជីវកម្មជាមួយអតិថិជនត្រូវបានបញ្ចប់។

**មាត្រា១២.** របាយការណ៍អំពីប្រតិបត្តិការសាច់ប្រាក់ ឬប្រតិបត្តិការសង្ស័យទៅ ស.ហ.ក

ត្រូវរាយការណ៍៖

- ប្រតិបត្តិការសាច់ប្រាក់ស្មើ ឬលើសចំនួនកំណត់
- ពេលបុគ្គលរាយការណ៍សង្ស័យ
- រាយការណ៍ជាបន្ទាន់ក្នុងរយៈពេល២៤ម៉ោង
- តាមមធ្យោបាយទំនាក់ទំនងឆាប់រហ័ស

# ជំពូកទី៣៖ វិធានការត្រូវប្រកាន់យកដោយបុគ្គលរាយការណ៍ (ត)

**មាត្រា១៣.** **ខ្លឹមសារនៃរបាយការណ៍ប្រតិបត្តិការសង្ស័យ**

របាយការណ៍ប្រតិបត្តិការសង្ស័យត្រូវមានភ្ជាប់មកជាមួយជាអប្បបរមា នូវ៖

១. អត្តសញ្ញាណ និងសញ្ញាណសម្គាល់នៃបុគ្គលរាយការណ៍

២. អត្តសញ្ញាណ និងសញ្ញាណសម្គាល់នៃអតិថិជន និងអត្ថគាហក

៣. ប្រភេទ និងព័ត៌មានលម្អិតនៃប្រតិបត្តិការ

៤. កាលៈទេសៈ និងហេតុផលផ្សេងៗ

**មាត្រា១៤.** **ការរួចផុតពីការទទួលខុសត្រូវចំពោះការរាយការណ៍ដោយសុចរិតនូវប្រតិបត្តិការសាច់ប្រាក់ ឬប្រតិបត្តិការសង្ស័យ**

នៅពេលបុគ្គល នាយក និយោជិត ឬបុគ្គលរាយការណ៍ បញ្ជូនព័ត៌មាន ឬរបាយការណ៍ទៅ **ស.ហ.ក** ដោយសុចរិត។

# ជំពូកទី៣៖ វិធានការត្រួតប្រកាន់យកដោយបុគ្គលរាយការណ៍ (ត)

**មាត្រា១៥.** ការហាមឃាត់ការផ្តល់ព័ត៌មាន៖

បុគ្គលដែលមានកាតព្វកិច្ចផ្តល់ព័ត៌មាន ឬបុគ្គលណាដែលបានដឹងរឿង មិនត្រូវផ្តល់ព័ត៌មាន ឬរាយការណ៍ទៅបុគ្គលផ្សេង លើកលែងមានការអនុញ្ញាតពី **ស.ហ.ក**។

**មាត្រា១៦.** ការត្រួតពិនិត្យផ្ទៃក្នុង និងការប្រតិបត្តិតាមរបស់បុគ្គលរាយការណ៍

ត្រូវបង្កើតកម្មវិធីទប់ស្កាត់ **AML/CFT** ដោយ៖

- បង្កើតគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យផ្ទៃក្នុង
- បណ្តុះបណ្តាលមន្ត្រីបុគ្គលិកជាប្រចាំ
- តែងតាំងមន្ត្រីប្រតិបត្តិជាមន្ត្រីថ្នាក់គ្រប់គ្រង
- មុខងារត្រួតពិនិត្យផ្ទៃក្នុង

**មាត្រា១៧.** មន្ត្រីប្រតិបត្តិ

ជាមន្ត្រីជាន់ខ្ពស់ ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ និងមានបទពិសោធន៍គ្រប់គ្រាន់។

**មាត្រា១៨.** កាតព្វកិច្ចសមស្រប និងត្រឹមត្រូវ

ក្រសួង ស្ថាប័នត្រួតពិនិត្យត្រូវធានាពីភាពសមស្រប និងត្រឹមត្រូវរបស់គណៈគ្រប់គ្រង និងភាគទុនិករបស់បុគ្គលរាយការណ៍។

# ជំពូកទី៤៖ ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

- ក្រុមប្រឹក្សាភិបាល មានតួនាទីពិគ្រោះយោបល់ និងផ្តល់អនុសាសន៍លើការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា៖

  - មានសិទ្ធិអំណាចធ្វើការសម្រេចចិត្តដោយឯករាជ្យ
  - ចេញសេចក្តីណែនាំទៅបុគ្គលរាយការណ៍
  - ត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែង ដើម្បីធានាការប្រតិបត្តិតាមច្បាប់របស់បុគ្គលរាយការណ៍
  - លើកសំណើអោយក្រសួង ស្ថាប័នត្រួតពិនិត្យអនុវត្តវិធានការត្រួតពិនិត្យ រួមមានការដាក់ទណ្ឌកម្ម ឬការដកហូតអាជ្ញាបណ្ណ
  - ដាក់ទណ្ឌកម្មខាងរដ្ឋបាល
  - ចុះកិច្ចព្រមព្រៀងជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេស។ល។

# ជំពូកទី៥៖ បទប្បញ្ញត្តិផ្សេងៗ

- **គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ** រៀបចំដាក់ចេញនូវគោលនយោបាយ ដឹកនាំ និងសម្របសម្រួលការអនុវត្តច្បាប់។
- **ការសម្របសម្រួលផ្ទៃក្នុងកម្រិតបច្ចេកទេស** អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក្រសួង ស្ថាប័នអនុវត្តច្បាប់ ក្រសួង ស្ថាប័នត្រួតពិនិត្យ ព្រមទាំងក្រសួង ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ដែលទទួលខុសត្រូវទប់ស្កាត់ ឬត្រួតពិនិត្យការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវបង្កើតយន្តការប្រតិបត្តិរៀងៗខ្លួន។

# ជំពូកទី៦៖ ការបង្កក ការឃាត់ទុក និងការរឹបអូស

❑ **ការបង្កក៖**

- បង្កកដោយសមាជិកដែលបានចាត់តាំងដោយគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ឬ
- បង្កកដោយ LEA ក្រោយដឹងថាមានទ្រព្យសម្បត្តិដែលពាក់ព័ន្ធ ឬសង្ស័យពាក់ព័ន្ធបទល្មើស ហើយត្រូវប្តឹងទៅតុលាការដើម្បីបង្កក។

❑ **ការរឹបអូស៖**

- ក្នុងស្ថានភាពមានទោសសម្អាតប្រាក់ តុលាការអាចចេញបទបញ្ជាអោយរឹបអូស
- ក្នុងករណីតុលាការរកឃើញបទល្មើស បើទោះជាចារីមិនទាន់ផ្តន្ទាទោសដោយសារមិនស្គាល់អត្តសញ្ញាណ ឬស្លាប់
- ទោសបន្ថែមដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ។

❑ **ទ្រព្យសម្បត្តិបញ្ចូលគ្នា៖** ក្នុងករណីនេះ ការរឹបអូសមិនត្រូវលើសតម្លៃនៃទ្រព្យសម្បត្តិដែលទាក់ទងនឹងបទល្មើស។

❑ **បន្ទុករបស់ជនជំទាស់នឹងសេចក្តីសម្រេច៖** ក្នុងករណីនេះ ជនជំទាស់ត្រូវបង្ហាញតុលាការថាខ្លួនមានសិទ្ធិត្រឹមត្រូវលើទ្រព្យសម្បត្តិដែលត្រូវបានរឹបអូស ហើយជាទ្រព្យសម្បត្តិមិនជាប់ពាក់ព័ន្ធនឹងបទល្មើស។

❑ **ការបង្កកមូលនិធិហិរញ្ញប្បទានភេរវកម្ម៖** ក្នុងករណីរកឃើញមូលនិធិរបស់ភេរវករ ឬអង្គការភេរវកម្ម ដូចក្នុង UNSCR 1267 និង UNSCR 1373 និងសេចក្តីសម្រេចបន្តបន្ទាប់ ត្រូវតែបង្កកដោយគ្មានពន្យារពេល។

# ជំពូកទី៧៖ ទោសប្បញ្ញត្តិ

១. ទណ្ឌកម្មខាងវិន័យ និងទណ្ឌកម្មខាងព្រហ្មទណ្ឌ

២. ទណ្ឌកម្មខាងវិន័យរួមមាន៖

ក. ការព្រមាន

ខ. ការស្តីបន្ទោស

គ. ការហាមឃាត់ ឬដាក់កំហិតមិនអោយធ្វើប្រតិបត្តិការណាមួយ ឬក្នុងយៈពេលមួយតាមការកំណត់របស់ក្រសួង ស្ថាប័នត្រួតពិនិត្យ

ឃ. ការដកហូតអាជ្ញាបណ្ណប្រកបអាជីវកម្ម

ង. ការស្នើអោយដកហូតតំណែងមន្ត្រី ឬនាយកចាត់ការដែលពាក់ព័ន្ធរបស់បុគ្គលរាយការណ៍ទាំងនោះ

ច. ការផាកពិន័យ

៣. ទណ្ឌកម្មខាងព្រហ្មទណ្ឌ រួមមានការពិន័យជាប្រាក់ និងការដាក់ពន្ធនាគារ

# ជំពូកទី៧៖ ទោសប្បញ្ញត្តិ (ត)

| | ពិន័យជាប្រាក់ | ពន្ធនាគារ | ព្រហ្មទណ្ឌ |
|---|---|---|---|
| មាត្រា៣៨៖ សម្អាតប្រាក់ | ១០០-៥០០ លានរៀល ឬរហូតដល់ស្មើតម្លៃមូលនិធិឬទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការសម្អាតប្រាក់ | ២ - ៥ ឆ្នាំ | |
| | ២០០-១,០០០ លានរៀល ព្រមទាំងទោសបន្ថែមមួយឬច្រើន | | អាចទទួលខុសត្រូវព្រហ្មទណ្ឌ |
| មាត្រា៣៩៖ ការបដិសេធផ្តល់ព័ត៌មាន | ១០-១០០ លានរៀល និង/ឬ | ៦ ថ្ងៃ - ១ ខែ | |
| | ៥០-២០០ លានរៀល ព្រមទាំងទោសបន្ថែមមួយឬច្រើន | | អាចទទួលខុសត្រូវព្រហ្មទណ្ឌ |
| មាត្រា៤០៖ ការខកខានមិនរាយការណ៍ CTR និង STR | ៥០-២០០ លានរៀល និង/ឬ | ១ ខែ - ១ ឆ្នាំ | |
| | ២០០-៥០០ លានរៀល ព្រមទាំងទោសបន្ថែមមួយឬច្រើន | | អាចទទួលខុសត្រូវព្រហ្មទណ្ឌ |
| មាត្រា៤១៖ ការរំលោភកាតព្វកិច្ចផ្តល់ព័ត៌មាន និងការហាមឃាត់ការផ្តល់ព័ត៌មាន | ៥០-២០០ លានរៀល និង/ឬ | ១ ខែ - ១ ឆ្នាំ | |
| | ២០០-៥០០ លានរៀល ព្រមទាំងទោសបន្ថែមមួយឬច្រើន | | អាចទទួលខុសត្រូវព្រហ្មទណ្ឌ |
| មាត្រា៤២៖ ការរំលោភតាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈ | ៥០-២០០ លានរៀល និង/ឬ | ១ ខែ - ១ ឆ្នាំ | |
| | ២០០-៥០០ លានរៀល ព្រមទាំងទោសបន្ថែមមួយឬច្រើន | | អាចទទួលខុសត្រូវព្រហ្មទណ្ឌ |
| មាត្រា៤៤៖ ហិរញ្ញប្បទានភេរវកម្ម | | ១០ - ២០ ឆ្នាំ | |
| | ១,០០០-២,០០០ លានរៀល | | អាចទទួលខុសត្រូវប្រហ្មទណ្ឌ |

# ជំពូកទី៨៖ អន្តរប្បញ្ញត្តិ

## ការបន្តសុពលភាព

- ច្បាប់ឆ្នាំ២០០៧ និងច្បាប់វិសោធនកម្មឆ្នាំ២០១៣ ត្រូវបាត់បង់អានុភាព និងជំនួសដោយច្បាប់នេះ
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តច្បាប់ឆ្នាំ២០០៧ និងច្បាប់វិសោធនកម្មឆ្នាំ២០១៣ មានអនុភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

# សូមអរគុណ!

